ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

អគ្គនាយកដ្ឋានយោធសេវា

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំអគ្គនាយកដ្ឋានយោធសេវា ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្រោយពីបានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះប្រព្រឹត្តិការណ៍ដ៏មានសារសំខាន់ជាអាយុជីវិតរបស់ប្រទេសជាតិពាក់ព័ន្ធទៅនឹងសវនាកាកាត់ទោស«រំលាយគណបក្សសង្គ្រោះជាតិ» របស់តុលាការកំពូលនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ យើងខ្ញុំសូមគាំទ្រទាំងស្រុងនិងយ៉ាងពេញទំហឹង ចំពោះសាលដីកាស្ថាពរដែលបាន « រំលាយគណបក្សសង្គ្រោះជាតិ » គឺពិតជាស័ក្តិសមទៅនឹងទោសកំហុស នៃទង្វើក្បត់ជាតិរបស់គណបក្សមួយនេះ ដែលបានប្រព្រឹត្តកន្លងមក។

យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រចំពោះវិធានការច្បាប់របស់តុលាការ និងសូមគោរព អនុវត្តតាមបទបញ្ជាដ៏ម៉ឺងម៉ាត់របស់ក្រសួងការពារជាតិ ជាពិសេសត្រៀមអនុវត្តបទបញ្ជាគ្រប់កាលៈទេសៈ ចំពោះវិធានការបន្តដែលដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទប់ស្កាត់ឧបាយកលពិសពុលនៃបដិវត្តន៍ពណ៌នៅកម្ពុជា។

សូមប្តេជ្ញារួមចំណែកថែរក្សា ការពារសន្តិសុខ សន្តិភាព និងការអភិវឌ្ឍនៅកម្ពុជា ប្រឆាំងដាច់ខាតរាល់ឧបាយកលរបស់ក្រុមអ្នកនយោបាយនិងជនអគតិមួយចំនួនដែលឃុបឃិតនិងបម្រើផលប្រយោជន៍បរទេស។ ប្តេជ្ញាការពារបូរណភាពទឹកដីនៃកម្ពុជា ប្រឆាំងនិងការជ្រៀតជ្រែកទាំងឡាយរបស់បរទេស។ ប្តេជ្ញាគាំទ្រការអនុវត្តវិធានការច្បាប់ និងការគោរពច្បាប់ក្នុងសង្គមដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំអគ្គនាយកដ្ឋានយោធសេវា ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ សូមគាំទ្រនិងសម្តែងនូវភក្តីភាពយ៉ាងស្មោះស្ម័គ្រ ចំពោះថ្នាក់ដឹកនាំក្រសួងការពារជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ ដែលតែងតែបានបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តម ប្រកបដោយមនសិការទទួលខុសត្រូវខ្ពស់ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។

យើងខ្ញុំទាំងអស់គ្នា សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើក្បត់ជាតិ របស់គណបក្សសង្គ្រោះជាតិ និងថ្នាក់ដឹកនាំក៏ដូចជាជនអគតិមួយចំនួន ដែលបានឃុបឃិតជាមួយបរទេស ព្រមទាំងប្រឆាំងដាច់ខាតរាល់ឧបាយកលបដិវត្តន៍ពណ៌ មិនឱ្យនាំមកនូវសង្គ្រាមវិនាសសកម្មនិងគ្រោះមហន្តរាយជាថ្មីម្តងទៀតនៅកម្ពុជានោះឡើយ។

សូមគាំទ្រឲ្យមានការចាត់វិធានការផ្លូវច្បាប់ជាបន្តបន្ទាប់ទៀតឱ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋ ក្នុងគោលបំណងថែរក្សា សន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**អគ្គនាយក**

នាយឧត្តមសេនីយ៍ **មាស សាវ៉ន**